**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**បាត់ដំបង**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៦០៨ ចុះថ្ងៃទី២៧
ខែសីហា ឆ្នាំ២០១៨
សាលក្រម
លេខ២៥(ខ)ចុះថ្ងៃទី០៩
ខែមករា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើ តាមព្រះរាជក្រមនស/រកម/០៧១៨/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ។

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០១៨ និងប្រកាសសាលក្រមនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាអនុប្រធានសាលាដំបូងខេត្តបាត់ដំបង
លោក [redacted] ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង

### ក្រឡាបញ្ជី

លោក [redacted] ក្រឡាបញ្ជីសវនាការ

### ដើម្បីជំនុំជំរះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៦០៨ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទមានដូចខាងក្រោមនេះ ៖

-ឈ្មោះ[redacted] ធឿត ហ ឆ្លូញ ភេទប្រុស អាយុ ១៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកើតនៅភូមិ[redacted] ខេត្តបាត់ដំបង នៅសព្វថ្ងៃនៅភូមិ[redacted] ខេត្តបាត់ដំបង មុខរបរកម្មករ នៅលីវ ឪពុកឈ្មោះ[redacted] ធឿន (រស់) ម្តាយឈ្មោះ[redacted] ស៊ាត (រស់)កំរិតវប្បធម៌ថ្នាក់ទី៣ទោសពីមុនគ្មាន ឃុំខ្លួនលេខ:៨៦៣ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨។

ពីបទ: រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនិងជនរងគ្រោះ ប្រព្រឹត្តនៅនៅចំណុចក្រុមទី១៧ ភូមិភ្នំប្រាំពីរ ឃុំបួរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញាតិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

លោក[redacted] ជាមេធាវីការពារឲ្យជនជាប់ចោទ ។

### ជនរងគ្រោះអវត្តមាន

ឈ្មោះ [redacted] លីណា ភេទស្រី អាយុ៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិភ្នំប្រាំពីរ ឃុំបួរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

Scanned with CamScanner

## ដើមបណ្ដឹងរដ្ឋប្បវេណីអវត្តមាន

ឈ្មោះ [redacted]សាម៉ន ភេទស្រី អាយុ៣៨ឆ្នាំ មានទីលំនៅភូមិភ្នំប្រាំពីរ ឃុំបួរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មុខរបរកម្មករ ។

លោកស្រី [redacted] ជាមេធាវីការពារដើមបណ្ដឹង-និងជនរងគ្រោះ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ១៨១៣ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់ព្រះរាជអាជ្ញាបានកំណត់ថា កាលពីថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង១២និង០០នាទី នៅចំណុចក្រុមទី១៧ ភូមិភ្នំប្រាំពីរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ជនត្រូវចោទឈ្មោះ [redacted] ធឿត ហៅ ឆ្លូញ ភេទប្រុស អាយុ១៥ឆ្នាំ បានបបួលជនរងគ្រោះឈ្មោះ [redacted]លីណា ភេទស្រី អាយុ៩ឆ្នាំ មើលរឿងតុក្កតាអាសអាភាសនៅលើផ្ទះតែ ២(ពីរ)នាក់ បន្តិចក្រោយមកស្រាប់តែជនត្រូវចោទរូបនេះចាប់ជនរងគ្រោះធ្វើឲ្យនាងរើបំរាស់មិនរួច ហើយស្រាតខោជើងវែងរបស់ជនរងគ្រោះចេញ ចាប់ឲ្យដេកផ្អៀងលើកជើងស្ដាំម្ខាងឡើងលើ រួចដកប្រដាប់ភេទរបស់ខ្លួនបញ្ចេញតាមជើងខោខ្លី ដាក់ចូលប្រដាប់ភេទរបស់ជនរងគ្រោះបានសម្រេច ។

ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខៈ ៦៣៩ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួបានបញ្ជូនជនជាប់ចោទ-ឈ្មោះ [redacted] ធឿត ហៅ ឆ្លូញ ភេទប្រុស អាយុ ១៥ឆ្នាំ ជាតិខ្មែរ និងសំណុំព្រហ្មទណ្ឌលេខ: ៦០៩ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ពីបទៈ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនិងជនរងគ្រោះ ប្រព្រឹត្តនៅនៅចំណុចក្រុមទី១៧ ភូមិភ្នំប្រាំពីរ ឃុំបួរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញាតិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

## នៅចំពោះមុខនាពេលសវនាការ

-ឈ្មោះ [redacted] ធឿត ហៅ ឆ្លូញ ជាជនជាប់ចោទបានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួននិងជនរងគ្រោះបានមើលទូរស័ព្ទដៃរឿងតុក្កតាសិចជាមួយគ្នា ខ្លួនក៏មានអារម្មណ៍ ជួនពេលនោះស្វាត់ល្អខ្លួនក៏ចាប់ស្រាតខោជនរងគ្រោះ ហើយបញ្ចេញប្រដាប់ភេទរបស់ខ្លួនតាមជើងខោ ដាក់ចូលប្រដាប់ភេទជនរងគ្រោះ ពេលនោះជនរងគ្រោះខំរើបំរាស់ដែរ តែមិនរួចព្រោះខ្លួនចាប់ជាប់ ។ ពេលរំលោភនោះគឺ ពីក្រោយគូទជនរងគ្រោះតែមិនចូលទេ គ្រាន់តែរុញៗពីលើប្រដាប់ភេទរបស់នាងតែប៉ុណ្ណោះ ។

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted]លីណា ជាជនរងគ្រោះបានឆ្លើយថា នៅថ្ងៃកើតហេតុ ឈ្មោះ [redacted] ធឿត បានបបួលខ្លួនមើលរឿងតុក្កតាសិចនៅលើផ្ទះតែពីរនាក់ ក្រោយមកស្រាប់តែជននេះបានចាប់ស្រាតខោរបស់ខ្លួន ឲ្យខ្លួនដេកផ្អៀង ហើយរំលោភខ្លួនបានសម្រេច០១ដង ។

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted]សាម៉ន ជាដើមបណ្ដឹងបានឆ្លើយថា នៅថ្ងៃកើតហេតុ ពេលខ្លួកំពុងអង្គុយលេងក្រោមផ្ទះ ស្រាប់តែកូនស្រីរបស់ខ្លួនចុះមកពីលើផ្ទះប្រាប់ថា ឈ្មោះ [redacted] ធឿតបានចាប់រំលោភ ពេលនោះនាងខ្ញុំក៏សួរឈ្មោះ [redacted] ធឿត បានឆ្លើយថា ពិតជាបានប្រព្រឹត្តអំពើបែបនេះមែន ខ្លួនក៏ប្ដឹងទៅសមត្ថកិច្ចតែម្ដង ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន

មានភស្តុតាង និង មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ជឿត ហា ឆ្នូញ ភេទប្រុស អាយុ១៥ឆ្នាំពីបទៈ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅនិងជនរងគ្រោះ ប្រព្រឹត្ត នៅនៅចំណុចក្រុមទី១៧ ភូមិភ្នំប្រាំពីរ ឃុំបួរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញាតិមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

## មេធាវីការពារជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា

ក្នុងរឿងនេះជនជាប់ចោទបានសារភាព តែលទ្ធផលនៃការប្រព្រឹត្តបទល្មើស គឺពុំបានសំរេច នោះទេជនល្មើសគ្រាន់តែយកប្រដាប់ភេទរបស់ខ្លួនញលៗទៅលើប្រដាប់ភេទ ជនរងគ្រោះពីក្រោយ តែប៉ុណ្ណោះទេគឺអត់ចូលទេហើយក្នុងសំណុំរឿងក៏គ្មានលិខិតកោសលវិច័យដែលបង្ហាញពីការដាច់ ដោចសន្ធះព្រហ្មចារីយ៍ជនរងគ្រោះទេ ម្យ៉ាងទៀតជនជាប់ចោទក៏ក្មេងមានអាយុទើបតែ១៥ឆ្នាំដូច្នេះ សូមឲ្យតុលាការប្តូរបទចោទទៅជាប្រទូស្តិ៍កេរខ្មាសតាមមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌវិញ និង សូមឲ្យតុលាការសំរេចទោសដោយជនជាប់ចោទជាអនីតិជនអាយុ១៥ឆ្នាំតាមមាត្រា ១៦០ ផង ។

-ក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-យពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយជនត្រូវចោទ

-ក្រោយពីបានពិនិត្យនិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបង
## យល់ឃើញថា

តាមអង្គហេតុដែលបានរៀបរាប់តាមរយៈចម្លើយសារភាពរបស់ជនជាប់ចោទ និងចម្លើយឆ្លើយឲ្យការរបស់ជនរងគ្រោះ តុលាការអាចកំណត់បានថា ៖

១-ជនជាប់ចោទគឺពិតជាមានចេតនាក្នុងការចាប់ជនរងគ្រោះដោយបង្ខំដើម្បីរួមភេទ មិនមែនគ្រាន់តែចង់ស្ទាបអង្អែលទៅតាមន័យ ដែលមានចែងក្នុងមាត្រា ២៤៦ នោះទេ គឺទៅតាម ន័យនៃមាត្រា ២៣៩ គឺរំលោភសេពសន្ថវៈ ។

២-បើនិយាយអំពីស្ថានទម្ងន់ទោសនោះវិញ គឺជនជាប់ចោទបានប្រព្រឹត្តទៅលើក្មេង ជាអនីតិជនអាយុទើបតែ៨ឆ្នាំនោះទេ ។

៣-បើនិយាយអំពីស្ថានសំរាលនោះវិញគឺ

៣-១-ជនជាប់ចោទទើបតែអាយុ១៥ឆ្នាំត្រូវទទួលបាននូវស្ថានសំរាលទោសតាម មាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

៣-២-ការប្រព្រឹត្តមិនបានប្រើអំពើហឹង្សាបោតធ្វើឲ្យជនរងគ្រោះមានរបួសស្នាម អ្វីនោះទេ ពីព្រោះម្តាយជនរងគ្រោះនៅក្រោមផ្ទះក៏មិនបានដឹងផង លុះត្រាតែជនរងគ្រោះប្រាប់ ទើបដឹង ។

Scanned with CamScanner

៣-៣-ការប្រព្រឹត្តរបស់ជនជាប់ចោទពុំបានសំរេចដល់ទិសដៅនៃបទល្មើសទេ គឺពុំបានចូលស៊ីជំរៅទៅក្នុងរន្ធប្រដាប់ភេទជនរងគ្រោះនោះទេ ។

៤-ក្នុងរឿងនេះម្តាយជនរងគ្រោះមិនបានចូលខ្លួនមកប្តឹងទាមទារសំណងរដ្ឋប្បវេណីទេ ចំណុចនេះតុលាការក៏មិនលើកយកមកពិចារណាដែរ ទុកសិទ្ធិឲ្យប្តឹងទៅតុលាការរដ្ឋប្បវេណីពេលក្រោយ ។

## ហេតុដូច្នេះ

## សម្រេច

-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ជឿត ហៅ ឆ្លូញ ភេទប្រុស អាយុ ១៥ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារកំណត់រយៈពេល ៤(បួន)ឆ្នាំ ។

ពីបទ: រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងទៅ និងជនរងគ្រោះ ប្រព្រឹត្តនៅចំណុចក្រុមទី១៧ ភូមិភ្នំប្រាំពីរ ឃុំបួរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញាតិមាត្រា ២៤១ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខានិងត្រា** [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**
**ហត្ថលេខានិងត្រា** [redacted]

........................................................................................................

បានចម្លងត្រឹមត្រូវតាមសាលក្រមដើម
ថ្ងៃពុធ ៤កើត ខែបុស្ស ឆ្នាំច សំរិទ្ធស័ក ពស២៥៦២
បាត់ដំបង ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩
**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**
បាត់ដំបង ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩
**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]

Scanned with CamScanner